**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៨

ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៧ **គាដ់ជាមប្រជារាស្ត្រខ្មែរ**

**សាលក្រមព្រហ្មទណ្ឌ** *សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការជំនុំជម្រះ*

លេខ: ០៩ (ច) *ជាសាធារណៈនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៨ ។*

ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៨ *ដោយមានសមាសភាព:*

១-លោក [redacted] *ប្រធានក្រុមប្រឹក្សាជំនុំជម្រះ*

២-លោក [redacted] *ចៅក្រមប្រឹក្សា*

៣-លោក [redacted] *ចៅក្រមប្រឹក្សា*

៤-លោក [redacted] *តំណាងអយ្យការ*

៥-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

*ដើម្បីជំនុំជម្រះលើជនជាប់ចោទ:*

១-ឈ្មោះ [redacted]ភេទប្រុស អាយុ ២៧ឆ្នាំ មុខរបរលាងម៉ូតូ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិពន្លៃ ឃុំពន្លៃ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ននៅភូមិចក ឃុំចក ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ[redacted](ស) ប្រពន្ធឈ្មោះ[redacted](រ) មានកូន ០១នាក់ ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី **២២ ខែ មិថុនា ឆ្នាំ២០១៧**)។

២-ឈ្មោះ [redacted]ភេទប្រុស អាយុ ១៧ឆ្នាំ មុខរបរកម្មករ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្វាយតយ ឃុំពន្លៃ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្ននៅភូមិចក ឃុំចក ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ[redacted](ស) នៅលីវ ទោសពីមុនគ្មាន (ឃុំខ្លួនថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៧)។

ត្រូវជាប់ចោទពីបទ: រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចក ឃុំចក ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted]



Scanned by CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៧ វេលាម៉ោង ១១ និង០០នាទី នៅចំណុចភូមិចក ឃុំចក ស្រុកបរិបូណ៍ ខេត្តកំពង់ឆ្នាំង កើតមានករណី រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ: [redacted] បានទិញថ្នាំញៀនមកលក់បន្តទៅឲ្យឈ្មោះ: [redacted] ចំនួន ០៣កញ្ចប់ ក្នុងតម្លៃ ១០០.០០០ (ដប់ម៉ឺន) រៀល ក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនបានតែម្តង ចំណែកឯឈ្មោះ: ផាត់ សុជាតិ ជាអ្នករស់នៅជាមួយឈ្មោះ: អែម ថារី ហើយបានធ្វើតេស្តទឹកនោមរកឃើញថាមានសារធាតុញៀនក្នុងខ្លួន និងបានយកលុយធ្លាក់ចំនួន ១០០.០០០ (ដប់ម៉ឺន) រៀល យកទៅដាក់ក្នុងកាបូបប្រពន្ធរបស់ឈ្មោះ [redacted]

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៥០៧ /១៧ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ ។

បានឃើញ ដីកាចាត់តាំងចៅក្រមប្រឹក្សាជំនុំជម្រះលេខ: ១១៦៤ /១៧ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

### នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ: [redacted] បានឆ្លើយថា: កាលពីថ្ងៃកើតហេតុ មានឈ្មោះ: [redacted] បានចេញពីផ្ទះខ្លួនប្រហែលជាប្រាំនាទី ក៏ត្រូវសមត្ថកិច្ចចុះមកឆែកឆេររកឃើញគ្រឿងញៀនចំនួន ០៧ កញ្ចប់ដែលជារបស់ខ្លួនទុកសម្រាប់ប្រើប្រាស់ ដើមដំបូងឈ្មោះ: [redacted] បានយកគ្រឿងញៀនពីខ្លួនចំនួនមួយកញ្ចប់ ហើយយកទៅលក់ឲ្យគេបានតម្លៃចំនួន ១០០.០០០(មួយរយពាន់) រៀល ហើយយកមកឲ្យខ្លួនវិញ ពេលនោះខ្លួនក៏យកទៅដាក់នៅលើគ្រែ ចំណែកគ្រឿងញៀនទាំងនោះខ្លួនទិញពីគេនៅក្រគរក្នុងតម្លៃមួយកញ្ចប់ ២០.០០០(ម្ភៃពាន់) រៀល ហើយឈ្មោះ: [redacted] គ្រាន់តែមកនៅក្នុងផ្ទះរបស់ខ្លួនតែប៉ុណ្ណោះ ។

-ចម្លើយជនជាប់ចោទឈ្មោះ: [redacted] បានឆ្លើយថា: កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៧ វេលាម៉ោង ១០ ព្រឹក ខ្លួនកំពុងតែដាក់បាយជ្រូកនៅក្រោយផ្ទះ ឃើញមានសមត្ថកិច្ចចុះទៅឆែកឆេរពុំឃើញមានអ្វីឡើយ កន្លងមកខ្លួនធ្លាប់ជក់គ្រឿងញៀននៅភ្នំពេញ ចំណែកនៅកំពង់ឆ្នាំងខ្លួនធ្លាប់ជក់គ្រឿងញៀនជាមួយឈ្មោះ: [redacted] ពោះប្រាក់ចំនួន ១០០.០០០(មួយរយពាន់) រៀល ខ្លួនឃើញនៅលើគ្រែ ខ្លួនក៏យកមកដាក់ក្នុងកាបូបរបស់ប្រពន្ធឈ្មោះ: [redacted] ខ្លួនពុំដឹងថាជាប្រាក់របស់នរណាឡើយ ។

-អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៧ ខ្លួន និងលោក [redacted] បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់គ្រឿងញៀនមួយករណី ដោយមានការណ៍សហការណ៍ពីកម្លាំងអធិការនគរបាលស្រុកបរិបូណ៍ ចុះបង្ក្រាបលើទីតាំងមួយកន្លែង ស្ថិតនៅភូមិចក ឃុំចក ស្រុកបរិបូណ៍ ខេត្តកំពង់ឆ្នាំង ដោយបានប្រើប្រាស់កម្លាំងប៉ូលីសបន្លំខ្លួនចូលទៅទិញដោយប្រើលុយធ្លាក់ចំនួន ១០០.០០០ (ដប់ម៉ឺន) រៀល ជាប្រភេទក្រដាសប្រាក់ ១០.០០០ (មួយម៉ឺន)រៀល គឺទិញបានចំនួន ១០កញ្ចប់ ហើយ



Scanned by CamScanner

ពេលចេញមកវិញគឺកម្លាំងសរុបចូលទៅព័ទ្ធចាប់បានតែម្តង សរុបមកសមត្ថកិច្ចបានឃាត់ខ្លួនបានមនុស្សចំនួន ០២ នាក់ គឺឈ្មោះ[redacted]និងឈ្មោះ[redacted]និងថ្នាំញៀនចំនួន ០៧កញ្ចប់ និងឧបករណ៍វេចខ្ចប់មួយចំនួនបញ្ជូនមកកម្លាំងសមត្ថកិច្ចក៏បានកសាងសំណុំរឿងតាមនីតិវិធី។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានស្នើសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ[redacted]ពីបទៈ រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំណែកឈ្មោះ[redacted] គ្រាន់តែបានប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ ស្នើសុំឲ្យលើកលែងពីបទ រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ ដោយចោទប្រកាន់តែការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តែប៉ុណ្ណោះ ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់។

-មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថា: ឆ្លងកាត់ការសួរដេញដោល កូនក្តីខ្លួនបានបដិសេធគ្រប់ដំណាក់កាល បើយោងតាមភស្តុតាងធាតុផ្សំនៃបទល្មើស ធាតុសត្យានុម័តអង្គហេតុកើតឡើងគឺពុំមានគំនិតជួញដូរដូចការចោទប្រកាន់ ទាំងកូនក្តីខ្លួនមិនដឹងខ្លួន ផ្ទុយទៅវិញគឺឈ្មោះ[redacted]ទេដែលបានប្រព្រឹត្ត ហើយការដកគ្រឿងញៀនគឺច្រើនដងពុំមែនជាអង្គហេតុក្នុងរឿងនេះទេ បើពិនិត្យមើលធាតុនៃសមគំនិតកូនក្តីខ្លួនពុំមានចេតនាទុច្ចរិតនោះទេក្នុងការជួញដូរនោះទេ សូមឲ្យតុលាការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួន ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយមន្ត្រីជំនាញ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថា:

១- តុលាការបានទទួលបណ្តឹង តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥០៩ /១៧ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបញ្ជូនជនជាប់ចោទ ១.ឈ្មោះ[redacted] ២.ឈ្មោះ[redacted]ពីបទៈ រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិចក ឃុំចក ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ចម្លើយជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា: នៅថ្ងៃកើតហេតុ ឈ្មោះ[redacted] បានយកគ្រឿងញៀនពីខ្លួនមួយកញ្ចប់ចំនួនទៅលក់ឲ្យអ្នកដទៃ ១០០.០០០(មួយរយពាន់) រៀល ហើយយកមកខ្លួន ហើយក៏យកដាក់លើគ្រែ ចំណែកឈ្មោះ[redacted] គ្រាន់តែមកស្នាក់នៅផ្ទះរបស់ខ្លួនតែប៉ុណ្ណោះ ។



Scanned by CamScanner

៣-ចម្លើយជនជាប់ចោទឈ្មោ[redacted]បានឆ្លើយថា: នៅថ្ងៃកើតហេតុ សមត្ថកិច្ចចុះមកឆែកឆេរខ្លួន ប៉ុន្តែពុំមានឃើញមានអ្វីឡើយ ចំណែកប្រាក់ចំនួន ១០០.០០០(មួយរយពាន់)រៀល ខ្លួនឃើញនៅលើគ្រែ ពុំដឹងជារបស់នរណាឡើយ ខ្លួនក៏យកមកដាក់ក្នុងកាបូបរបស់ប្រពន្ធឈ្មោ[redacted]

៤-ចម្លើយមន្ត្រីនគរបាលឈ្មោះ[redacted]បានឆ្លើយថា: នៅថ្ងៃកើតហេតុ ខ្លួនបានប្រើកម្លាំងជាធ្លាក់ទៅទិញគ្រឿងញៀន រហូតឈានដល់ការឃាត់ខ្លួនបានឈ្មោះ[redacted]និងឈ្មោ[redacted]

៥-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានស្នើសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ[redacted] ពីបទ: រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំណែកឈ្មោះ[redacted] គ្រាន់តែបានប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ ស្នើសុំឲ្យលើកលែងពីបទ រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ ដោយចោទប្រកាន់តែការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តែប៉ុណ្ណោះ ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់។ ការប្តឹងសុំរបស់តំណាងអយ្យការ តុលាការឯកភាពខ្លះ មិនឯកភាពខ្លះ ទោះបីជាជនជាប់ចោទឈ្មោះ[redacted]ព្យាយាមបដិសេធ ហើយពេលប្រតិបត្តិការឆែកឆេរពុំឃើញមានគ្រឿងញៀន ប៉ុន្តែទំនាក់ទំនងរវាងឈ្មោះ[redacted] និងឈ្មោះ[redacted]មានលក្ខណៈស្និទ្ធស្នាល មិនត្រឹមតែប៉ុណ្ណោះឈ្មោះ[redacted]ថែមទាំងមានទំនាក់ទំនងជាមួយនឹងឈ្មោះ[redacted]ដែលជាអ្នកជួញដូរគ្រឿងញៀនផងដែរ ហើយឈ្មោះ[redacted]ថែមទាំងបានយកប្រាក់ដែលបានមកពីការលក់គ្រឿងញៀនទៅដាក់ក្នុងកាបូបប្រពន្ធរបស់ឈ្មោះ[redacted]ទៀត ទាំងនេះហើយដែលគប្បីតុលាការពិចារណាឃើញ ថាជនជាប់ចោទពុំមែនគ្រាន់តែប្រើប្រាស់គ្រឿងញៀនទេ ថែមទាំងបានសមគំនិតក្នុងការជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៦-មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថា: ឆ្លងកាត់ការសួរដេញដោល កូនក្តីខ្លួនបានបដិសេធគ្រប់ដំណាក់កាល បើយោងតាមភស្តុតាងធាតុផ្សំនៃបទល្មើស ធាតុសត្យានុម័តអង្គហេតុកើតឡើងគឺពុំមានគំនិតជួញដូរដូចការចោទប្រកាន់ ទាំងកូនក្តីខ្លួនមិនដឹងខ្លួន ផ្ទុយទៅវិញគឺឈ្មោ[redacted]ដែលបានប្រព្រឹត្ត ហើយការជក់គ្រឿងញៀនគឺច្រើនដងពុំមែនជាអង្គហេតុក្នុងរឿងនេះទេ បើពិនិត្យមើលធាតុនៃសមគំនិតកូនក្តីខ្លួនពុំមានចេតនាទុច្ចរិតនោះទេក្នុងការជួញដូរនោះទេ សូមឲ្យតុលាការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួន ។ ការស្នើសុំរបស់មេធាវី តុលាការមិនអាចពិចារណាបានឡើយ ព្រោះបទល្មើសគ្រឿងញៀនជាបទល្មើសលាក់កំបាំងមិនងាយមើលឃើញជាទូទៅសមត្ថកិច្ចបានប្រើប្រាស់កម្លាំងជាធ្លាក់ទើបឃាត់ខ្លួនបានជនល្មើសទាំងពីរនាក់នេះ ម្យ៉ាងទៀតឈ្មោះ[redacted]មិនគ្រាន់តែស្នាក់នៅផ្ទះឈ្មោ[redacted]នាមជាអ្នកជទៃធម្មតានោះឡើយ ហើយពេលលក់គ្រឿងញៀនបានប្រាក់មិនមែនឈ្មោះ[redacted] យកប្រាក់ទៅទុកនៅគ្រែ ហើយឈ្មោះ[redacted] បានដាក់ក្នុងកាបូបរបស់ប្រពន្ធឈ្មោះ[redacted]ហាក់ដូចជាដឹងអំពីប្រភពសាច់ប្រាក់ ។

៧-ឆ្លងកាត់ការសួរដេញដោលក្នុងសវនាការ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ការស្នើសុំរបស់មេធាវី តុលាការពិចារណាបានថា នៅថ្ងៃកើតហេតុជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ទោះបីជាជនជាប់ចោទឈ្មោះ[redacted]ព្យាយាមបដិសេធ ប៉ុន្តែរាល់ទំនាក់ទំនងរវាងឈ្មោះ[redacted] ឈ្មោះ[redacted] និងឈ្មោះ[redacted]ក្នុងការដែលឈ្មោ[redacted]កគ្រឿងញៀនពីឈ្មោះ[redacted]លក់បន្ត និងឈ្មោះ[redacted] ទោះបីជាព្យាយាមបដិសេធ ប៉ុន្តែការដែលឈ្មោះ[redacted]យកលុយចំនួន ១០០.០០០(មួយរយពាន់) រៀល ដែលបានមកពីការលក់គ្រឿងញៀន យកទៅទុកក្នុងកាបូបរបស់ភរិយាឈ្មោះ[redacted]ាចសន្និដ្ឋានឲ្យតុលាការជឿថាឈ្មោះ[redacted]ពិតជាដឹងពីប្រភពសាច់ប្រាក់យ៉ាងច្បាស់ ដូច្នេះរាល់សកម្មភាពរបស់ជនជាប់ចោទទាំងពីរពិត



Scanned by CamScanner

ជាអាចបញ្ជាក់ឲ្យតុលាការយ៉ាងច្បាស់ថាឈ្មោះ: [redacted] និងឈ្មោះ [redacted] ជារឺបានសមគំនិតក្នុងការជួញដូរ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។

៨-ដោយសារជនជាប់ចោទឈ្មោះ: [redacted] ជាអនីតិជន ដូច្នេះការផ្តន្ទាទោសចំពោះជនជាប់ចោទ តុលាការនឹងពិចារណាលើមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

៩-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទ:

៩.១-ឈ្មោះ: [redacted] ភេទប្រុស អាយុ ១៧ ឆ្នាំ ។

៩.២-ឈ្មោះ: [redacted] ទប្រុស អាយុ ២៧ ឆ្នាំ ។

ពីបទ: រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិចក ឃុំចក ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-វត្ថុតាងរួមមាន: ទូរសព្ទដៃចំនួន ០២គ្រឿង គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ .ម៉្សៅក្រាមពណ៌សថ្លា សង្ស័យជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ចំនួន ០៨ កញ្ចប់តូច (ទម្ងន់ ១.៨៥ ក្រាម) និងឧបករណ៍ជក់ និងឧបករណ៍វេចខ្ចប់ថ្នាំញៀនមួយចំនួន គប្បីតុលាការរឹបអូស និងបំផ្លាញចោល ។

១១-ជនជាប់ចោទជានីតិជនឈ្មោះ: [redacted] និងឈ្មោះ: [redacted] ជាអនីតិជនដែលពុំមានភស្តុតាងឬសញ្ញាណបញ្ជាក់ថាកើតមានវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននេះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើប្រព្រឹត្តរបស់ខ្លួន អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម របៀបរៀបរយសាធារណៈ គោលនយោបាយភូមិឃុំ សុវត្ថិភាព និងបំពានច្បាប់។

## **<u>ហេតុដូច្នេះសម្រេច</u>**

១-ផ្តន្ទាទោសជនជាប់ចោទ:

១.១-ឈ្មោះ: [redacted] ភេទប្រុស អាយុ ១៧ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០១(មួយ) ឆ្នាំ ។

១.២-ឈ្មោះ: [redacted] ភេទប្រុស អាយុ ២៧ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣ (បី) ឆ្នាំ ។

ពីបទ: រក្សាទុក ជួញដូរ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិចក ឃុំចក ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែង ឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមាន: ទូរសព្ទដៃចំនួន ០២គ្រឿង តុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ .ម៉្សៅក្រាមពណ៌ សថ្លា សង្ស័យជាសារធាតុញៀនប្រភេទមេតំហ្វេតាមីន ចំនួន ០៨ កញ្ចប់តូច (ទម្ងន់ ១.៨៥ ក្រាម) និងឧបករណ៍ជក់ និងឧបករណ៍វេចខ្ចប់ថ្នាំញៀនមួយចំនួន តុលាការរឹបអូស និងបំផ្លាញចោល ។



Scanned by CamScanner

៣-សាលក្រមនេះជនុំជម្រះនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |



Scanned by CamScanner